ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ. ធ៥-០២៥-១២៧០ សរ.ល

ថ្ងៃព្រហស្បតិ៍ ៣កើត ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៥

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់ទម្រង់ "បញ្ជាផ្ទេរប្រាក់ក្រៅប្រទេស" ថ្មី តាមរយៈធនាគារជាតិនៃកម្ពុជា

ធនាគារជាតិនៃកម្ពុជា សូមជម្រាបជូនដំណឹងដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាម្ចាស់គណនីនៅធនាគារជាតិនៃកម្ពុជាទាំងអស់ មេត្តាជ្រាបថា ធនាគារជាតិនៃកម្ពុជា បានដាក់ដំណើរការជាផ្លូវការនូវស្តង់ដារអន្តរជាតិ ISO 20022 ក្នុងប្រព័ន្ធស្វីហ្វ (SWIFT) សម្រាប់ប្រតិបត្តិការផ្ទេរប្រាក់ទៅក្រៅប្រទេស នៅនាយកដ្ឋានសេវាធនាគារ កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៥។ ការអនុវត្តតាមស្តង់ដារអន្តរជាតិ ISO 20022 នេះ ទាមទារឱ្យម្ចាស់គណនីផ្តល់ព័ត៌មានចាំបាច់មួយចំនួនឱ្យបានត្រឹមត្រូវ គ្រប់គ្រាន់ និងច្បាស់លាស់ ដើម្បីធានាប្រតិបត្តិការផ្ទេរប្រាក់ទៅក្រៅប្រទេសប្រព្រឹត្តទៅដោយពិលាស ឆាប់រហ័ស និងចប់ជាស្ថាពរ។

ក្នុងន័យនេះ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលមានបំណងធ្វើប្រតិបត្តិការផ្ទេរប្រាក់ទៅក្រៅប្រទេស តាមរយៈនាយកដ្ឋានសេវាធនាគារនៃធនាគារជាតិនៃកម្ពុជា ត្រូវប្រើប្រាស់ **"បញ្ជាផ្ទេរប្រាក់ក្រៅប្រទេស"** ថ្មី ដូចមានជូនភ្ជាប់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាម្ចាស់គណនីនៅធនាគារជាតិនៃកម្ពុជាទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងសហការអនុវត្ត។

ទន្ទឹមនេះ រាល់ខ្លឹមសារទាំងឡាយណាដែលផ្ទុយពីស្មារតីនៃសេចក្តីជូនដំណឹងនេះ ត្រូវចាត់ទុកជានិរាករណ៍។

សេចក្តីជូនដំណឹងនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**អគ្គនាយកប្រតិបត្តិការ**

**គីមធី ភោមលី**

សូមស្កេនដើម្បីទាញយក
"បញ្ជាផ្ទេរប្រាក់ក្រៅប្រទេស"

Logo
(Letter Head)

លេខ ....................................

# បញ្ជាផ្ទេរប្រាក់ក្រៅប្រទេស
**Oversea Transfer Order**

## ព័ត៌មានអ្នកផ្ទេរប្រាក់

- អ្នកផ្ទេរប្រាក់៖ ..........................................................................
- លេខកូដស្វ៊ីហ្វ (Swift/ BIC Code) ..........................................................................
- អាសយដ្ឋាន៖ ផ្លូវ ............................. អគារ ......................... លេខកូដប្រៃសណីយ៍ (Postal Code) .......................
  ខណ្ឌ / ស្រុក / ក្រុង .................................. រាជធានី / ខេត្ត ......................... ប្រទេស ......................
- លេខគណនី៖ ..........................................................................
- ចំនួនប្រាក់៖ .................................................................... (ជាអក្សរ ..........................................................................
  ..........................................................................)
- គោលបំណងនៃការផ្ទេរប្រាក់៖ ..........................................................................
  .......................................................................... លេខកូដគោលបំណង ..........................
- កម្រៃផ្ទេរប្រាក់ជាបន្ទុករបស់៖ ☐ អ្នកផ្ទេរប្រាក់ / ☐ អ្នកទទួលប្រាក់

## ព័ត៌មានអ្នកទទួលប្រាក់

- អ្នកទទួលប្រាក់៖ ..........................................................................
- លេខកូដស្វ៊ីហ្វ (Swift/ BIC Code) ..........................................................................
- អាសយដ្ឋាន៖ ផ្លូវ ........................... អគារ ......................... លេខកូដប្រៃសណីយ៍ (Postal Code) ...........................
  ខណ្ឌ / ស្រុក / ក្រុង .................................. រាជធានី / ខេត្ត ......................... ប្រទេស ......................
- លេខគណនី៖ ...................................................... លេខ IBAN ..........................................................................

## ព័ត៌មានធនាគារអ្នកទទួលប្រាក់

- ធនាគារអ្នកទទួលប្រាក់៖ ..........................................................................
- លេខកូដស្វ៊ីហ្វ (Swift/ BIC Code) ..........................................................................
- លេខកូដប្រព័ន្ធផាត់ទាត់ជាតិ (National Clearing System Code): ..........................................................................
- លេខគណនី៖ ...................................................... លេខ IBAN ..........................................................................

## ព័ត៌មានធនាគារអន្តរការី

- ធនាគារអន្តរការី៖ ..........................................................................
- លេខកូដស្វ៊ីហ្វ (Swift/ BIC Code) ..........................................................................

ថ្ងៃ ...................................... ខែ ............. ឆ្នាំ ............. ព.ស. ............

............................... ថ្ងៃទី ........ ខែ ............. ឆ្នាំ .............

**ម្ចាស់គណនី / អ្នកមានសិទ្ធិ**